

# ដំណាំស្លែក្តោប

## ១.ការរៀបចំដី

●ភ្ជួរដីជម្រៅ២តឹកទៅ៣តឹក(២០សង់ទីម៉ែត្រ ទៅ៣០សង់ទីម៉ែត្រ)

● ភ្ជួររាស់ដីឲ្យបានម៉ដល្អ ហើយហាលវាពី១០ ទៅ១៥ថ្ងៃមុនដាំកូនស្លែក្តោប



**ការលើករងដាំ៖**

កសិករត្រូវចាប់ផ្តើមលើករងដាំកូនស្លែក្តោបឲ្យរួចរាល់មុនអាយុកាលកូនត្រូវដាំ។ របៀបធ្វើរងដាំស្លែក្តោបមានដូចខាងក្រោម៖

- ទទឹងរង១ម៉ែត្រ
- បណ្តោយ រងធ្វើតាមលទ្ធភាពតែមិនគួរលើស ពី ២៥ ម៉ែត្រទេ។ ការលើករងវែងពេកកសិករនឹងពិបាកចូលស្រោចទឹក ធ្វើស្មៅដាក់ជីបាញ់ថ្នាំ និងប្រមូលផល។
- លើករងនៅរដូវវស្សាគួរមានកំពស់ពី៣តឹក ទៅ៥តឹក(៣០សង់ទីម៉ែត្រ-៥០សង់ទីម៉ែត្រ)
- ចន្លោះពីគុម្ពមួយ ទៅគុម្ពមួយមានប្រវែង៥០ សង់ទីម៉ែត្រ
- ចន្លោះពីជួរមួយ ទៅជួរមួយមានប្រវែង៥០ សង់ទីម៉ែត្រ




● ច្របល់ជីលាមកសត្វពុកផុយ ឬជីកំប៉ុស្ត ១-២ គីឡូក្រាមលាយជាមួយជី អិន ប៉េ កា(២០.២០.១៥) ចំនួន១០ក្រាម (១ស្លាបព្រាបាយ)សំរាប់ស្លែក្តោប ១ដើម ឬ ជី ២០.២០.១៥ ចំនួន៦,៤ គីឡូក្រាម សម្រាប់ផ្ទៃដី ៥០០ម²។ ជៀសវាងដាក់ជីលាមកសត្វមិនទាន់ពុកផុយទ្រាប់បាតពីព្រោះវាបង្កឲ្យកូនស្លែក្តោបរលួយបន្ទាប់ពីដាំហើយ។

**ផលប្រយោជន៍នៃការដាក់ជីទ្រាប់បាត៖**

● ដាក់ជីលាមកសត្វ ពុកផុយ ឬជីកំប៉ុស្តទ្រាប់បាតជួយឲ្យដីធូ ឫសងាយដុះលូតលាស់

● ដាក់ជី អិន ប៉េ កា ទ្រាប់បាតវាជំរុញកូនបន្លែទើបដាំរួចដុះឫសបានច្រើននិងរឹងមាំ ហើយដើមនិងស្លឹកលូតលាស់បានឆាប់រហ័ស។



## ២. ការធ្វើរោងបណ្តុះកូនស្លែក្តោប

● ត្រូវសង់រោង នៅកន្លែងណាដែលមានពន្លឺថ្ងៃគ្រប់គ្រាន់ និងមិននៅក្បែរដើមឈើ

● ធ្វើដំបូលប្លាស្ទីក ពណ៌ស ដើម្បីឲ្យពន្លឺថ្ងៃចាំងចូលកូនបន្លែ គ្រប់គ្រាន់នៅរដូវវស្សា និងរដូវប្រាំងធ្វើដំបូលពីសំណាញ់កាត់ពន្លឺ។ ជៀសវាងធ្វើដំបូលរោងកូនបន្លែពីស្លឹកដូង តង់ពណ៌ខៀវ ឬពីសម្ភារៈផ្សេងទៀត ដែលមិនអាចឲ្យពន្លឺថ្ងៃចូល និងធ្វើគ្រាប់បន្លែដុះយឺត ដើមកូនបន្លែទន់ ឬរលួយ។

● ដំបូលរោងមានកំពស់ ពី២ -២.៥ម៉ែត្រ

● រានបណ្តុះគួរមានកំពស់កន្លះម៉ែត្រពីដី

●រានបណ្តុះអាចធ្វើពីឫស្សី ក្តារ និងសម្ភារៈដទៃទៀតអាចរកបាន។ មិនត្រូវក្រាលដី បាវក្រចៅឬសម្ភារៈណាដែលជក់ទឹកនៅខាងក្រោមកន្ទោង ឬថាស់បណ្តុះនោះទេ ពីព្រោះវាអាចនាំមកជាមួយនូវជំងឺ និងធ្វើឲ្យឫសចាក់ចុះហួសកន្ទោងបណ្តុះនាំឱ្យដាច់ឫស នៅពេលដកយកទៅដាំ។

● គ្របសំណាញ់សត្វល្អិតពណ៌ស



រានបណ្តុះកូនបន្លែសម្រាប់រដូវប្រាំង

## ៣. ការបណ្តុះគ្រាប់ស្លែក្តោប

**ការរៀបចំដីបណ្តុះគ្រាប់:**

យកដីមានជីជាតិ១ ភាគលាយជាមួយជីលាមកគោស្ងួត ឬជីកំប៉ុស្តិ៍២ភាគ និងផេះអង្កាម ពី២ ទៅ ៣ ភាគ អាស្រ័យតាមប្រភេទដី (ផេះអង្កាមត្រូវត្រាំទឹករយះពេល ពី២ ទៅ ៣យប់) ។ យកល្បាយដែលបាន លាយច្របល់ហើយទៅលីងឬចំហុយរហូតក្តៅសព្វ តែត្រូវឲ្យដីនោះនៅសើមតិចៗទើបមិនខូចគុណភាពដី។



* ស្រោចទឹកឲ្យជោគដីបណ្តុះមុនដាក់គ្រាប់
* ដាក់គ្រាប់ស្លែក្តោប ១គ្រាប់ ក្នុង១ប្រហោះថាសបណ្តុះ ឬ១កន្ទោងរួចយកដីរោយលុបពីលើគ្រាប់។ មិនត្រូវកប់គ្រាប់ជ្រៅក្នុងដីបណ្តុះ នោះទេ វាអាចធ្វើឲ្យគ្រាប់រលួយ ឬដុះយឺត។

## ៤ . ការដាំកូនស្លែក្តោប

កូនស្លែក្តោបមានអាយុ២២-២៥ថ្ងៃ (មានស្លឹកបី)យើងយកវាទៅដាំបាន។ បើយើងដាំវាមានអាយុចាស់ជាងនេះ យើងនឹងខាត ផលប្រយោជន៍ដូចជា៖

* កូនស្លែក្តោបខ្សោយ(ស្គមៗ) និងលូតលាស់

យឺតបន្ទាប់ពីដាំហើយ

⁕ មានក្តោបតូចៗ

⁕ កាត់បន្ថយទិន្នផល

-- ត្រូវពង្រឹងកូនស្ពៃក្តោប ចំនួន៥ថ្ងៃ មុនដកយកដាំ (ត្រូវដាក់កូនស្ពៃក្តោប ឲ្យត្រូវពន្លឺថ្ងៃ តែជៀសវាងពេលថ្ងៃត្រង់) និងបន្ថយការស្រោចទឹករហូតដល់ពេលយកកូនទៅដាំ។





រងបានបញ្ចូលទឹកនៅពេលព្រឹកត្រៀមដាំកូនស្ពៃក្តោបពេលរសៀល

## ៥. ការថែទាំ

### ក. ប្រភេទជីនិងពេលវេលាប្រើប្រាស់ជី ៖

ពូជស្ពៃក្តោបបង្កាត់ (អ៊ីប្រីដ) ត្រូវដាក់ជីបំប៉នឲ្យបានទៀងទាត់ ទើបវាអាចផ្តល់ក្តោបបានធំ និងរលោងជាការប្រសើរគួរដាក់ជីបំប៉នរៀងរាល់៧ទៅ១៥ថ្ងៃម្តង បន្ទាប់ពីដាំកូនស្ពៃក្តោបហើយ តែវាអាស្រ័យទៅតាមរដូវកាល ប្រភេទដី និងស្ថានភាពលូតលាស់ស្ពៃក្តោបផងដែរ។ ឧទាហរណ៍ប្រភេទដីខ្សាច់ត្រូវដាក់ជីឲ្យបានញឹកញាប់ តែដាក់បរិមាណតិច ដោយសារប្រភេទដីនេះងាយហូរច្រោះជី ទឹកលឿន ដូច្នេះបើយើងដាក់ជីច្រើន នោះវានឹងបាត់បង់ដោយសារហូរតាមទឹក ហើយដំណាំស្រូបយកបានតិចតួច ។

### ខ. ការស្រោចទឹក

⁕ បន្ទាប់ពីដាំកូនហើយរហូតដល់អាយុបាន២អាទិត្យត្រូវស្រោចទឹកកូនស្ពៃក្តោបរៀងរាល់ថ្ងៃដើម្បីឲ្យដើមស្លឹក ឫសដុះបានរឹងមាំ

⁕ បញ្ចូលទឹកតាមចន្លោះរងឲ្យជោគនាពេលព្រឹក

⁕ បើពិនិត្យនៅក្បែរគល់ស្ពៃក្តោបឃើញដីសើមខ្លាំង យើងគួរកាត់បន្ថយស្រោចទឹក តែបើដីនោះស្ងួតរហូតពុំអាចលុញជាគ្រាប់ឃ្លីបាន យើងត្រូវប្រញាប់ស្រោចទឹកភ្លាម

⁕ ការខកខានស្រោចទឹកជាកត្តាមួយធ្វើឱ្យដើមក្រិន ក្តោបមិនរីកលូតលាស់បានល្អធំរលោង





## ៦. សត្វល្អិតចង្រៃ

### ដង្កូវស៊ីបណ្តូលស្ពៃក្តោប៖

កូនដង្កូវស៊ីត្រួយខ្ចី ចោះចូលទៅក្នុងបណ្តូល និងផ្នែកខាងក្រៅក្តោប។ ដង្កូវនេះបានបផ្លាញត្រួយបណ្តូល នៃក្តោបបង្កឲ្យស្ពៃ មិនអាចក្តោបបាន។ សំបុករបស់វាស្ថិតនៅផ្នែកខាងលើនៃស្លឹកខាងក្នុង។ កញ្ចុំសំបុកពងរបស់វាងាយឃើញនៅលើស្លឹកផ្នែកខាងក្រោមដើម។

### វិធីការពារ

⁕ យើងត្រូវគ្របស្បែសត្វល្អិត ការពារកូនស្ពៃក្តោបរហូតដល់ពេលយកកូនដាំហើយ

⁕ ភ្ជួរ រាស់ ហាលដីឱ្យបានច្រើនសារ និងកុំដាំប្រភេទបន្លែដំដែលៗលើដីតែមួយ

⁕ កំចាត់ស្មៅចង្រៃ និងប្រមូលកាកសំណល់ផ្សេងៗចេញពីចំការ

⁕ ដាំស្ពៃក្តោបដោយប្រើប្លាស្ទីកគ្របដី។

## ៧. ការប្រមូលផល

យើងអាចប្រមូលផលបាននៅពេលមានអាយុពី៥៨ -៩៥ ថ្ងៃ (អាស្រ័យតាមប្រភេទពូជ) បន្ទាប់ពី ដាំកូន៕




## ឯកសារយោង:

១. សៀវភៅណែនាំបច្ចេកទេស ផលិតកម្មដំណាំបន្លែ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង East -West Seed International ខែធ្នូ ឆ្នាំ២០១៤

២. សៀវភៅបច្ចេកទេសដាំបន្លែនាយកដ្ឋានសាវប្បកម្ម និងដំណាំរួមផ្សំ និងកម្មវិធីវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM) ជាតិ នៃអគ្គនាយកដ្ឋានកសិកម្ម ឆ្នាំ២០១៣ ៕





ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម


# ព្រឹត្តបត្រព័ត៌មាន ស្តីពី ដំណាំស្ពៃក្តោប




រៀបចំចងក្រងដោយ៖

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ:

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

Agriculture Services Programme for Innovation, Resilience and Extension (ASPIRE)

ឆ្នាំ២០១៦



**សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកៈ**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

តាមអាស័យដ្ឋាន ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : ០២៣ ២១៥ ៨១៩/០១២ ៨៣ ៧៩ ៤៥

ទូរសារលេខ : ០២៣ ២១០ ៩៤៨

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម / Department of Agricultural Extension

គេហទំព័រ : http://www.maff.gov.kh

អ៊ីម៉ែល : info@maff.gov.kh